**ធនាគារជាតិ នៃ កម្ពុជា**

លេខ ៩៤២៦.០២៥.៨៨១.គរ.ន.ស

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

*ថ្ងៃសុក្រ ១៤កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨*
*រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៥*

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដេញថ្លៃប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) លើកទី២១៨

ធនាគារជាតិនៃកម្ពុជា សូមជូនដំណឹងដល់គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់ឱ្យបានជ្រាបថា ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) លើកទី២១៨ ដែលមានគណប្រតិទាន ៧ថ្ងៃ ៩១ថ្ងៃ និង១៨២ថ្ងៃ នឹងត្រូវដាក់ឱ្យដេញថ្លៃនៅថ្ងៃព្រហស្បតិ៍ ទី១៧ ខែមេសា ឆ្នាំ២០២៥។ ចំពោះការទូទាត់សម្រាប់ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) លើកទី២១៨ គ្រប់គណប្រតិទាននឹងត្រូវធ្វើឡើងនៅក្នុងថ្ងៃដដែល ។ ព័ត៌មានពាក់ព័ន្ធនឹងការដេញថ្លៃនេះ មានដូចតទៅ៖

- -ពេលវេលាដាក់ដេញថ្លៃ : ចាប់ពីម៉ោង ៨:០០ ព្រឹក ដល់ ០៩:០០ ព្រឹក
- -នីតិវិធីដេញថ្លៃ : ទឹកប្រាក់ដាក់ដេញថ្លៃជាលានរៀល (លេខមូល) និងអត្រាការប្រាក់ដាក់ដេញថ្លៃជាភាគរយ (ពីរខ្ទង់ក្រោយក្បៀស)
- -វត្ថុធានា : - NCD ឬ មូលបត្ររដ្ឋ ជាវត្ថុធានាត្រូវមានគណប្រតិទានវែងជាង ឬស្មើនឹងគណប្រតិទានរបស់ LPCO
  - គ្រឹះស្ថានអាចប្រើប្រាស់សមតុល្យក្នុងគណនីចរន្តជាវត្ថុធានាបាន
- -ហៃខាត់លើវត្ថុធានាជាដុល្លារអាមេរិក : ៣%
- -ទំហំទឹកប្រាក់ដេញថ្លៃអប្បបរមា : ២០០.០០០.០០០ (ពីររយលាន) រៀល
- -ទំហំទឹកប្រាក់ដេញថ្លៃអតិបរមា : មិនកំណត់

ទំហំទឹកប្រាក់ដាក់ឱ្យដេញថ្លៃ អត្រាការប្រាក់ និងថ្ងៃគណប្រតិទាន មានដូចតទៅ៖

| ប្រភេទ LPCO | ថ្ងៃគណប្រតិទាន | ទឹកប្រាក់ដាក់ឱ្យដេញថ្លៃ | អត្រាការប្រាក់ដាក់ដេញថ្លៃអប្បបរមា |
|---|---|---|---|
| ៧ថ្ងៃ(D07) | ២៤ មេសា ២០២៥ | ២៥០.០០០.០០០.០០០ រៀល | ៣,០០% |
| ៩១ថ្ងៃ (D91) | ១៧ កក្កដា ២០២៥ | ៥០.០០០.០០០.០០០ រៀល | ៣,២៥% |
| ១៨២ថ្ងៃ (D182) | ១៦ តុលា ២០២៥ | ២៥.០០០.០០០.០០០ រៀល | ៣,៥០% |



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ការដេញថ្លៃនឹងធ្វើតាមរយៈថ្នាលធនាគារជាតិនៃកម្ពុជា (NBCP) តាមកាលវិភាគដែលបានកំណត់។ ក្នុងករណី NBCP មិនអាចអនុវត្តបាន គ្រឹះស្ថានត្រូវបញ្ជូនពាក្យសុំដេញថ្លៃតាមសារអេឡិចត្រូនិក marketoperations@nbc.gov.kh ឬដាក់ក្នុងស្រោមសំបុត្របិទជិត និងផ្ញើមកនាយកដ្ឋានទីផ្សាររូបិយវត្ថុ ឱ្យបានមុនម៉ោង ០៩:០០ ព្រឹក នៅថ្ងៃដេញថ្លៃ។

លទ្ធផលនៃការដេញថ្លៃនឹងប្រកាសក្រោយបញ្ចប់ការដេញថ្លៃ នាថ្ងៃដដែល។ គ្រឹះស្ថានដែលដេញថ្លៃឈ្នះត្រូវអនុវត្តតាមសេចក្តីណែនាំលើការអនុវត្តប្រតិបត្តិការ LPCO។

គណៈកម្មាធិការដេញថ្លៃរក្សាសិទ្ធិក្នុងការកែប្រែលក្ខខណ្ឌនៃការដេញថ្លៃប្រតិបត្តិការ LPCO។

**សូមទំនាក់ទំនង៖ នាយកដ្ឋានទីផ្សាររូបិយវត្ថុ**
លេខទូរស័ព្ទ : (៨៥៥-២៣) ៩៩០ ១៩០
សារអេឡិចត្រូនិក : markets.info@nbc.gov.kh

**បណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា៖**
www.nbc.gov.kh , www.facebook.com/nationalbankofcambodiaofficial ,
www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia ,
www.linkedin.com/company/national-bank-of-cambodia ,
www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA